ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

សៀវភៅបច្ចេកទេស

# ការកែលម្អវិធីសាស្ត្រចិញ្ចឹមមាន់ លក្ខណៈគ្រួសារ



សម្រាប់កសិករ

២០១១

# សារៈសំខាន់នៃការអានសៀវភៅនេះ



១.ឱ្យកសិករ ចេះបច្ចេកទេសចិញ្ចឹមមាន់ក្នុងរបងជាលក្ខណៈគ្រួសារ ដោយផ្ដល់នូវចំណីដែលមានគុណភាព ដើម្បីទទួលបានផលចំណេញ និងមានសុវត្ថិភាព។

២.ឱ្យកសិករយល់ដឹងអំពីអត្ថប្រយោជន៍នៃការចិញ្ចឹមមាន់ជាលក្ខណៈគ្រួសារ។



ម.ព.ឯ.ក AIDOC
Code: 230-009
Date:
Donated by:

# ផ្លាស់ប្តូរពី:

**-ការចិញ្ចឹមតាមទំលាប់ (ព្រលែង):** គ្មានជប្រក គ្មានការផ្តល់ចំណី គ្មានការថែទាំសុខភាព និងគ្មានការចាក់ថ្នាំការពារឱ្យបានត្រឹមត្រូវ





## មកជា:

**-ការចិញ្ចឹមមាន់ក្នុងរបងជុំវិញទ្រុងនៅក្បែរផ្ទះ:** កសិករបានលទ្ធភាពផ្តល់ចំណី និងថែទាំសុខភាពរបស់មាន់បានល្អ និងចាក់ថ្នាំការពារសុខភាពឱ្យមាន់បានល្អ។

# អត្ថប្រយោជន៍នៃការចិញ្ចឹមមាន់ក្នុងរបងជាលក្ខណៈគ្រួសារ

មាន់ត្រូវបានចិញ្ចឹមនៅក្នុងរបងក្បែរផ្ទះ

↓

- ការពារមាន់បានល្អ
- ងាយស្រួលក្នុងការតាមដានសុខភាពរបស់មាន់
- ងាយស្រួលក្នុងការផ្តល់ចំណី-ទឹក

មាន់ត្រូវបានផ្តល់ឱ្យនូវចំណីធម្មជាតិ

↓

- ចំណាយទុនតិច ពីព្រោះអាចប្រើធនធានចំណីនៅជុំវិញផ្ទះ និងក្នុងភូមិ
- ចំណីមានគុណភាពល្អគ្មានជាតិគីមី

↓

មាន់មានសុខភាពល្អ និងមិនងាយឈឺស្លាប់



ស៊ុត និងសាច់សំរាប់បរិភោគ



ទទួលបានកូនមាន់សុខភាពល្អទុកធ្វើពូជ (មាន់មេមួយក្បាលផ្តល់កូនប្រមាណ ៦០ក្បាល/ឆ្នាំ)



បង្កើនប្រាក់ចំណូលពីការលក់មាន់

# ស្ត្រីដើរតួនាទីយ៉ាងសំខាន់នៅក្នុងការងារចិញ្ចឹមមាន់

-ជាលក្ខណៈប្រពៃណីសង្គមខ្មែរ ស្ត្រីបានតួនាទីធ្វើការងារនៅជុំវិញផ្ទះ ពួកគាត់អាចចិញ្ចឹមសត្វផង និងធ្វើកិច្ចការផ្ទះបានទៀតផងក៏ដូចជាការដាំដុះផ្សេងៗ

-វាងាយស្រួលគ្រប់គ្រង និងត្រូវការទុនតិច

-ផ្តល់ចំណូលដល់ស្ត្រីសម្រាប់ផ្គត់ផ្គង់គ្រួសារ ដែលជួយលើកកំពស់បុខបាត់ពួកគាត់ក្នុងគ្រួសារនិងក្នុងសង្គម និងធ្វើឱ្យស្ត្រីបានសិទ្ធិអំណាចក្នុងការសម្រេចចិត្ត

-វត្ថុធាតុដើមភាគច្រើន គឺពួកគាត់អាចរកបាននៅក្នុងភូមិ-ស្រុក ដោយមិនបាច់ត្រូវធ្វើដំណើរទៅរកទិញឆ្ងាយពីផ្ទះ

-ផ្តល់ជាអាហារសម្រាប់រូបគាត់ និងគ្រួសារ ដោយកាត់បន្ថយការចំណាយបានមួយចំនួនលើចំណីអាហារ

*បុរសនិងស្ត្រីសុទ្ធតែបានតួនាទីក្នុងការងារចិញ្ចឹមមាន់ដូចគ្នា វាផ្តល់ឱ្យពួកគាត់នូវឱកាស ក្នុងការចូលរួមធ្វើផែនការនិងបំពេញការងាររួមគ្នា ដើម្បីធ្វើឱ្យប្រសើរឡើង នូវទំនាក់ទំនងជាមួយគ្នា និងការធ្វើសេចក្តីសម្រេចចិត្តរួមគ្នា*

